# *ព្រះវិហារបុរាណវត្តដំណាក់*

*នៅតាមបណ្ដោយដងស្ទឹងសៀមរាប[១] ស្ថិតនៅកណ្ដាលក្រុងសៀមរាប មានវត្តជាច្រើនដែលទំនងកសាងឡើងក្នុងកាលបរិច្ឆេទប្រហាក់ប្រហែលគ្នា ហើយមានទឹកដៃសិល្បៈយ៉ាងល្អឯកគួរឱ្យកត់សម្គាល់។ វត្តដំណាក់ស្ថិតនៅត្រើយខាងកើត ដងស្ទឹងដែលមានព្រះវិហារបុរាណមួយសង់នៅលើខឿនខ្ពស់ ជញ្ជាំងថ្ម ដំបូលប្រក់ក្បឿងស្រកាលេញយ៉ាងល្អផ្ចិត (រូបលេខ១)។ ព្រះវិហារនេះត្រូវគេមើលឃើញថា គឺជាសំណង់ព្រះពុទ្ធសាសនាល្អប្លែកមួយនៅក្នុងតំបន់ ដែលលើកយកអន្ទើនានាក្នុងទេពកថារាមកេរ្តិ៍ឆ្លាក់នៅលើសន្ទឹកទ្វារ និងបង្អួច។ ចំណែកលើផ្ទៃជញ្ជាំងខាងក្នុង ពុំមានគំនូរដូចបណ្ដាព្រះវិហារផ្សេងៗឡើយ តែមានសន្ទឹកសីមាថ្មធំៗព័ទ្ធជុំវិញល្វែងគ្រឹះ (រូបលេខ២)។*





*រូបលេខ១ ព្រះវិហារមើលមើលពីជ្រុងអាគ្នេយ៍ រូបលេខ២ ផ្នែកខាងក្នុងព្រះវិហារ*

*បើយោងតាមការសិក្សារបស់ Daniel Guéret និង Dominique-Pierre Guéret សន្និដ្ឋានថាព្រះវិហារវត្តដំណាក់សាងសង់ឡើងនៅចុងសតវត្សទី១៩។[២] ប៉ុន្តែបើតាមសំណេររបស់ Peter Olszewski ផ្សាយលើទំព័រកាសែតភ្នំពេញប៉ុស្ដិ៍យល់ថា ព្រះវិហារវត្តដំណាក់កសាងឡើងក្នុងរវាងឆ្នាំ១៩១៩។[៣] ការសន្និដ្ឋានរបស់ Peter Olszewski ប្រហែលផ្អែកលើចំណារលេខ១៩១៩នៅលើជញ្ជាំងខាងជើង តែអ្នកខ្លះយល់ថាគឺជាឆ្នាំជួសជុលព្រះវិហារលើក*

---

*[១] ស្ទឹងសៀមរាបមានប្រភពចេញពីភ្នំគូលែន ដែលជាទីបូជនីយដ្ឋាន ជាទីសក្ការៈខ្លាំងបំផុតរបស់ខ្មែរ ដែលបានរៀបចំប្រសិទ្ធីពីភ្នំធម្មជាតិទៅជាភ្នំកៃលាសនាស.វ.ទី៩។*

*[២] Daniel Guéret & Doninique-Pierre Guéret 2017: 142*

*[៣] Peter Olszewski 2010 (https://www.phnompenhpost.com/siem-reap-insider/discovering-whats-wat-siem-reap)*

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*

*ដំបូង។ ប៉ុន្តែបើផ្អែកលើលក្ខណៈទូទៅនៃសំណង់ និងរូបថតឯកសារចាស់បំផុតរបស់បារាំងពាក់ព័ន្ធនឹងវត្តដំណាក់ គេអាចសន្និដ្ឋានបានថា ព្រះវិហារវត្តដំណាក់ប្រហែលសាងសង់ក្នុងរវាងមុនទសវត្សរ៍ទី២០។ ប៉ុន្តែយ៉ាងណាក្តីគេមើលឃើញថាព្រះវិហារវត្តដំណាក់ គឺជាព្រះវិហារបុរាណដ៏ល្បីល្បាញក្នុងខេត្តសៀមរាបតាំងពីដើមរៀងមក។ នៅក្នុងសម័យសង្គមរាស្ត្រនិយម ព្រះវិហារវត្តនេះក៏បានស្ថិតនៅលើទំព័រផ្សព្វផ្សាយអំពីអនុស្សាវរីយ៍រីកចម្រើននៃរបបសង្គមរាស្ត្រនិយមផងដែរ (រូបលេខ២៣)។*



*រូបលេខ២៣ ព្រះវិហារវត្តដំណាក់ផ្សព្វផ្សាយពីការរីកចម្រើនព្រះពុទ្ធសាសនាក្នុងសម័យសង្គមរាស្ត្រនិយម (រូបថត៖ ដកស្រង់ពីសៀវភៅអនុស្សាវរីយ៍សង្គមរាស្ត្រនិយម)*

*ព្រះវិហារវត្តដំណាក់ គឺជាប្រភេទព្រះវិហារបុរាណ ឬគេហៅថាវិហារជហ្វា៤ (រូបលេខ២៤)។[៨] ព្រះវិហារសង់នៅលើខឿនជាថ្នាក់ៗ ហើយនៅតាមចំហៀងខឿនជុំវិញ គេឃើញមានស្វាកស្នាមបញ្ចុះអដ្ឋិធាតុ ដែលជាទំនៀមខ្មែរប្រតិបត្តិមកតាំងពីបុរាណកាល (រូបលេខ២៥)។[៩] ចំពោះផ្នែកខាងមុខព្រះវិហារ គេសង់បន្តជាដំបូលរានហាលនៅផ្នែកខាង*

---

[៨] *សូមអានបន្ថែម "សំណង់នៅតាមវត្ត" ដោយ ព្រាប ចាន់ម៉ារ៉ា ២០១៧: ១៣-២៣*

[៩] *ញឹម សុជាវិន្ទ, Marui Masako, និង Miyamoto Yasuharu ២០២០: ១២*

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*

មុខដូចព្រះវិហារវត្តរាជបូព៌ ឬព្រះវិហារវត្តលោមព្រលឹង ដែលជាព្រះវិហារបុរាណក្នុងខេត្តសៀមរាបដែរ។ ព្រះវិហារវត្តដំណាក់ គេរៀបចំឱ្យមានជណ្ដើរឡើងទាំងបួនទិស ខាងកើតមានទ្វារ៣ ខាងលិចមានទ្វារ២ ចំហៀងទាំងសងខាងមានបង្អួច១៤ (ជើង៧ ត្បូង៧) ដំបូលប្រក់ក្បឿងស្រកាលេញជ្រាលចុះពីរថ្នាក់ (រូបលេខ២៤)។ ចំណែកឯនៅផ្នែកខាងក្នុងមានសសរឈើ៨ជ្រុង ចំនួន១២ដើម ទ្រគ្រឿងបង្គុំឈើផ្នែកខាងលើ។ រីឯនៅលើផ្ទៃជញ្ជាំងខាងក្នុងពុំមានគំនូរ ឬក្បាច់លម្អឡើយ ពោលគឺជាផ្ទៃលាតលាបពណ៌លឿងស្រាល។ រីឯផ្នែកខាងលើជាពិតានឈើ ហើយផ្ទៃធ្នឹមលម្អដោយក្បាច់ពណ៌ទឹកមាស។ ដោយឡែកនៅលើផ្ទៃសន្ទឹកទ្វារ និងបង្អួច (ផ្នែកខាងក្រៅ) ទាំងអស់ គេឆ្លាក់តួអង្គសំខាន់ៗ ឬទិដ្ឋភាពក្នុងរឿងរាមកេរ្តិ៍ លាបលម្អទឹកមាសយ៉ាងរស់រវើកគួរឱ្យកោតសរសើរ។



រូបលេខ២៤ ដំបូលព្រះវិហារវត្តដំណាក់ ជាវិហារជហ្វាបួន



រូបលេខ២៥ ស្នាកស្នាមនៃទំនៀមបញ្ចុះអដ្ឋិធាតុ និងឈ្មោះចារនៅលើខឿនជុំវិញព្រះវិហារវត្តដំណាក់

ដោយឡែកនៅលើហោជាងទាំងសងខាងនៃព្រះវិហារវត្តដំណាក់ គេឆ្លាក់ជាក្បាច់រចនាអំពីស៊ីម៉ង់ត៍ ដែលបង្ហាញអំពីទិដ្ឋភាពជានិមិត្តរូបពាក់ព័ន្ធនឹងព្រះពុទ្ធសាសនា។ ហោជាងខាងកើត គេឆ្លាក់ព្រះស្តូបចេតិយមួយយ៉ាងធំ ដែលមានពន្លឺឆព្វណ្ណរង្សីនៅកំពូលខាងលើ អមដោយឆ័ត្ររួតមួយគូ និងទេវតាពីរអង្គហោះហើរព្រោះព្រំ។ ចំណែកនៅផ្នែកខាងក្រោម អមព្រះស្តូបចេតិយ គេឆ្លាក់ជារូបទេពប្រណម្យ(?) ម្ខាង២អង្គ។ ផ្ទៃខាងក្រោយ គេឆ្លាក់ក្បាច់ភ្ញីទេសយ៉ាងរស់រវើក (រូបលេខ២៦)។ រីឯនៅនៅលើហោជាងខាងលិច គេឆ្លាក់អន្ទើសំខាន់មួយក្នុងរឿងពុទ្ធប្រវត្តិ គឺត្រង់ពេលព្រះអង្គចេញបួស។ ចម្លាក់ត្រង់នេះគឺមានតួអង្គព្រះសិទ្ធត្ថ(អនាគតព្រះពុទ្ធអង្គ) គង់លើខ្នងសេះ ទ្រង់គ្រឿងជាក្សត្រ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

មានទេវតាបួនអង្គទ្រដើងសេះ ទេពនិករហែហម និងអាមាត្រតោងជាប់កន្ទុយសេះ (រូបលេខ២៧)។ ចំណែកឯនៅផ្ទៃហោជាងខាងក្រោយ គេឆ្លាក់ក្បាច់ភ្ញីទេសយ៉ាងរស់រវើក ដូចហោជាងខាងកើតដែរ។ គួរកត់សម្គាល់ដែរថា ការរចនាហោជាងធ្វើអំពីស៊ីម៉ងត៍នៅលើព្រះវិហារបុរាណបែបនេះក៏ជាការកម្រ និងបង្ហាញឱ្យឃើញពីភាពទំនើបក្នុងសំណង់ដែរ ដ្បិតភាគច្រើនព្រះវិហារបុរាណគេនិយមឆ្លាក់ហោជាងលើឈើ។



រូបលេខ២៦ ហោជាងខាងកើត



រូបលេខ២៧ ហោជាងខាងលិច

ចំពោះរចនាសម្ព័ន្ធសំណង់ផ្នែកខាងក្រោមដំបូលវិញ គេឃើញថាព្រះវិហារនេះសង់ឱ្យមានបាំងសាចខាងក្រៅជញ្ជាំង។ មិនតែប៉ុណ្ណោះ ការលម្អត្រង់ចន្លោះសសរជុំវិញបាំងសាច ដោយរចនាជាបន្ទាត់កោងផ្កាប់ និងក្បាច់លម្អតូចៗផងនោះ ហាក់បង្ហាញឱ្យឃើញលក្ខណៈទំនើបមួយផ្នែកទៀតនៅក្នុងស្ថាបត្យកម្ម ពោលគឺជាទម្រង់សិល្បៈបែបបស្ចិមប្រទេសប្រើជាផ្នែកតូចមួយក្នុងសំណង់បុរាណខ្មែរ។ ប៉ុន្តែទោះជាបែបនេះក្តី គេមើលឃើញថាការលម្អនៅលើសន្ទឹកទ្វារ និងបង្អួចនីមួយៗសុទ្ធតែឆ្លាក់បង្ហាញអន្ទើផ្សេងៗក្នុងរឿងរាមកេរ្តិ៍ ដែលជាលក្ខណៈពិសេសមួយនៃព្រះវិហារវត្តដំណាក់[៦]។

ប្រសិនបើសង្កេតដោយត្រួសៗ នៅលើសន្ទឹកទ្វារទាំងបីនៃជញ្ជាំងខាងកើត ត្រង់ទ្វារកណ្តាល គេឆ្លាក់បង្ហាញត្រង់ព្រះលក្ខណ៍ប្រយុទ្ធនឹងវិរុលមុខកុមារដែលកាឡាខ្លួនជាឥន្ទ្រជិតនៅលើសន្ទឹកទ្វារទាំងសងខាង (រូបលេខ២៨)។ ចំណែកឯនៅលើទ្វារខាងត្បូង សន្ទឹកទ្វារម្ខាងគេឆ្លាក់ឥន្ទ្រជិតបំបាំងខ្លួនក្នុងពពក ហើយសន្ទឹកទ្វារម្ខាងទៀត គេ

[៦] ហៀន សុវណ្ណមរកត: ២០២១( https://ams.com.kh/khmercivilization/detail/13899)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ឆ្លាក់សិម្ពលីគ្រុឌកំពុងឆាបឆក់បំផ្លាញសរនាគបាសរបស់ឥន្ទ្រជិត ដែលមានទ័ពស្វាជុំវិញ (រូបលេខ៩)។



រូបលេខ៨ ព្រះលក្ស្មណ៍ប្រយុទ្ធនឹងវិរុលមុខកុមារ ដែលកាឡាខ្លួនជាឥន្ទ្រជិត



រូបលេខ៩ សិម្ពលីគ្រុឌឆាបឆក់បំផ្លាញសរនាគបាសរបស់ឥន្ទ្រជិត

ចំណែកទ្វារខាងលិច លើទ្វារស្តាំគេឆ្លាក់រូបតួអង្គសំខាន់ពីរគឺ ហនុមាននិងនាងបុញ្ញកាយ។ សន្លឹកទ្វារម្ខាង គឺឆ្លាក់ហនុមានចាប់នាងបុញ្ញកាយហោះចេញពីភ្លើង ហើយសន្លឹកទ្វារម្ខាងទៀត ឆ្លាក់រូបហនុមានហោះទ្រនាងបុញ្ញកាយ (រូបលេខ១០)។ ចំពោះឈុតត្រង់នេះ នៅក្នុងសាច់រឿងរាមកេរ្តិ៍រៀបរាប់ថា ក្រោយព្រះរាមទតឃើញសពនាងសីតាជាមហេសី (នាងបុញ្ញកាយកាឡាខ្លួន) អណ្តែតទឹកនៅចំពោះព្រះភ័ក្ត្រ ហនុមានបានយកសពសីតាទៅបូជាពិសោធរកការពិត ទើបលេចនាងបុញ្ញកាយហោះចេញពីភ្លើង។ ប៉ុន្តែពេលដឹងការពិតដូច្នេះ ព្រះរាមយល់ថានាងជាកូនរបស់ពិភេក ក៏ចាត់ឱ្យហនុមានហោះ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ជូននាងទៅក្រុងលង្ការវិញ។ រីឯនៅលើទ្វារខាងឆ្វេងនៃទិសខាងលិចនេះដែរ ប្រហែលគេឆ្លាក់រូបនាងបុញ្ញកាយនិងក្រុងរាពណ៍ជាឪពុកមា (រូបលេខ១១)។[៦]



រូបលេខ១០ ហនុមាននិងនាងបុញ្ញកាយ



រូបលេខ១១ នាងបុញ្ញកាយនិងក្រុងរាពណ៍

ក្រៅពីការឆ្លាក់សាច់រឿងនៅលើសន្ទឹកទ្វារនៃព្រះវិហារវត្តដំណាក់នេះ គេឃើញថានៅលើសន្ទឹកបង្អួចទាំង១៤ ក៏មានការឆ្លាក់បង្ហាញឈុតឆាកចម្បាំងតទល់គ្នារវាងព្រះរាម-ព្រះលក្ស្មណ៍ និងក្រុងរាពណ៍-ឥន្ទ្រជិត។ នៅលើបង្អួចខាងជើង ពលព្រះព្រះរាមចេញក្បួនពីឆ្វេង ទ័ពឥន្ទ្រជិតចេញពីស្តាំ។ រីឯលើសន្ទឹកបង្អួចខាងត្បូង ទ័ពព្រះរាមចេញពីស្តាំ ទ័ពឥន្ទ្រជិតចេញពីឆ្វេង ហើយចូលទល់ទ័ពប្រយុទ្ធគ្នានៅចំត្រង់បង្អួចកណ្តាល។

[៦] នាងបុញ្ញកាយជាកូនរបស់ពិភេក ដែលជាប្អូនរបស់ក្រុងរាពណ៍។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

សង្ខេបសេចក្ដីមក ព្រះវិហារវត្តដំណាក់ គឺជាសំណង់មួយដែលបង្ហាញឱ្យឃើញពីការចាប់ផ្ដើមភាពទំនើបនៃស្ថាបត្យកម្មក្នុងសំណង់បុរាណខ្មែរ។ ចំណែកឯការលើកយកឈុតឆាក ទិដ្ឋភាព និងតួអង្គសំខាន់ៗនៃរឿងរាមកេរ្តិ៍ដូចរៀបរាប់ខាងលើ គេអាចសន្និដ្ឋានបានថា គឺសាច់រឿងត្រង់អន្ទើចម្បាំងឥន្ទ្រជិត។ សាច់រឿងអន្ទើនេះផ្ដើមពីក្រុងរាពណ៍បង្គាប់នាងបុញ្ញកាយកាឡាខ្លួនជាសាកសពនាងសីតាអណ្ដែតទឹក ឱ្យព្រះរាមយល់ថានាងសីតាជាមហេសីសោយទិវង្គត។ ប៉ុន្តែផ្ទុយទៅវិញ ល្បិចនោះបានក្លាយជាហេតុនៃចម្បាំងកាន់តែខ្លាំងក្លាដែលគេស្គាល់ជាទូទៅថា "ចម្បាំងឥន្ទ្រជិត" ហើយល្បីល្បាញរហូតមានលើកមកសម្ដែងក្នុងទម្រង់ល្ខោនស្បែកធំទៀតផង៕

## ឯកសារយោង


ញឹម សុធារិទ្ធ, Marui Masako, និង Miyamoto Yasuharu

២០២០, "ជំនឿ និងការប្រតិបត្តិដែលពុំចេះដាច់នៅអង្គរ៖ តាមរយៈកំណាយបុរាណវិទ្យានៅបន្ទាយក្ដី", *ព្រះនគរ,* លេខ២, ទំ.១-២២, សៀមរាប, អាជ្ញាធរជាតិអប្សរា

ព្រាប ចាន់ម៉ារ៉ា

២០១៧. *សំណង់នៅតាមវត្ត*, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ

Daniel Guéret & Dominique-Pierre Guéret

2017, *The Khmer Pagoda,* Kam editions

Peter Olszewski

2020, 'Discovering what's wat in Siem Reap', *Phnom Penh Post,* https://www.phnompenhpost.com/siem-reap-insider/discovering-whats-wat-siem-reap

ហៀន សុវណ្ណមរកត

២០២១. *រឿងរាមកេរ្តិ៍នៅវិហារវត្តដំណាក់* (https://ams.com.kh/khmercivilization/detail/13899)


អត្ថបទដោយ៖ ហៀន សុវណ្ណមរកត